# ជំរុញការនាំចេញមាសស របស់កម្ពុជា[១]

## សេចក្ដីផ្ដើម

សេដ្ឋកិច្ចកម្ពុជាកើនឡើងយ៉ាងលឿនក្នុងទសវត្សរ៍កន្លងទៅ ។ ពីឆ្នាំ ១៩៩៨-២០០៨ ផសស របស់កម្ពុជា កើនបាន ៩,១% ក្នុងមួយឆ្នាំៗ ។ មានការមូលមតិថា កំណើនដ៏ខ្ពស់នេះ ជំរុញឡើងជាសំខាន់ដោយវិស័យ កាត់ដេរ សំណង់ និងទេសចរណ៍ ។ ទោះយ៉ាងនេះក្ដី សេដ្ឋកិច្ចកម្ពុជាភាគច្រើន នៅតែពឹងផ្អែកលើកសិកម្មនៅតាមទីជនបទនៅឡើយ ។ ទោះបីចំណែករបស់កសិកម្មក្នុង ផសស បានធ្លាក់ចុះជាបណ្ដើរៗក្ដី ក៏ក្នុងឆ្នាំ២០០៨ វានៅមានចំណែកដល់ ២៦% ក្នុង ផសស និងបានផ្ដល់ការងារដល់ជាង ៥៦% នៃកំលាំងពលកម្មសរុបនៅកម្ពុជា ។ ប្រហែល ៨០% នៃប្រជាជនកម្ពុជាសព្វថ្ងៃរស់នៅតំបន់ជនបទ និងពឹងផ្អែកលើកសិកម្ម ។

ជាមធ្យម វិស័យកសិកម្មមានកំណើនទាបជាង វិស័យឧស្សាហកម្ម និងសេវាកម្ម ។ ពីឆ្នាំ១៩៩៨-២០០៨ វិស័យកសិកម្មមានអត្រាកំណើនប្រមាណ ៤,២% ក្នុង១ឆ្នាំ ធៀបនឹង ៩,៩% សំរាប់វិស័យសេវាកម្ម និង ១៤,២% សំរាប់វិស័យឧស្សាហកម្ម ។ ក្នុងទសវត្សរ៍២០០០ កំណើនវិស័យកសិកម្មពីមួយឆ្នាំទៅមួយឆ្នាំបានឡើងចុះមិនទៀងទាត់ជាខ្លាំង ហើយជួនកាលមានកំណើនអវិជ្ជមានទៀតផង ក្នុង ៥ឆ្នាំ ដើមទសវត្សរ៍២០០០ ប៉ុន្តែចាប់ពីឆ្នាំ២០០៥ មក វាមានកំណើនវិជ្ជមានជាប់រហូត ។ នៅឆ្នាំ២០០៩ កំណើនវិស័យកសិកម្ម មានប្រហែល ៥% ស្របពេលដែលកំណើនប៉ាន់ស្មាននៃ ផសស ស្ថិតនៅក្នុងចន្លោះពី -២,២% ដល់ +០,១% ។

ដោយសារមានអាកាសធាតុតំបន់ត្រូពិច សំបូរដីដាំដុះ និងមានកំលាំងពលកម្មគ្មានជំនាញច្រើន កម្ពុជាមានឧត្ដមភាពក្នុងវិស័យកសិកម្ម ។ គេទទួលស្គាល់ជាទូទៅថា ការជំរុញវិស័យកសិកម្ម (កសិឧស្សាហកម្ម) ជាយុទ្ធសាស្ត្រល្អបំផុត សំរាប់ពង្រីកមូលដ្ឋានសេដ្ឋកិច្ច ទប់ទល់ការប៉ះទង្គិចខាងម៉ាក្រូសេដ្ឋកិច្ច ធានាសន្តិសុខស្បៀង កែលំអជីវភាពប្រជាជននៅតាមជនបទ និងកាត់បន្ថយភាពក្រីក្រ ។

ផលដំណាំមានចំណែកធំបំផុតក្នុងវិស័យកសិកម្ម បន្ទាប់មកគឺ ផលនេសាទ សត្វចិញ្ចឹម និងផលពីព្រៃឈើ ។ នៅឆ្នាំ២០០៨ ផលដំណាំមានចំណែក ៥៣% នៃផលិតផលកសិកម្ម ឬកើនឡើង ១២ឯកតាភាគរយ ធៀបនឹងឆ្នាំ១៩៩៨ (12 points more than in 1998) ហើយកំណើននេះ បានមួយផ្នែកមកពីការធ្លាក់ចុះនៃផលនេសាទ និងផលពីព្រៃឈើ ។ ផលិតផលកសិកម្មចំបងៗ គឺមានស្រូវ ពោត ដំឡូងឈើ សណ្ដែកសៀង ថ្នាំជក់ និងកៅស៊ូ ។ ស្រូវ អង្ករ ជាអាហារមូលដ្ឋាននៅកម្ពុជា និងមានចំណែកជាមធ្យម ៥៥%

១ លោក តុង គឹមស៊ុន អ្នកសម្របសម្រួលកម្មវិធីសេដ្ឋកិច្ច ពាណិជ្ជកម្ម និងសហប្រតិបត្តិការក្នុងតំបន់ នៃវិទ្យាស្ថាន CDRI បានពិនិត្យឡើងវិញ ពីការអភិវឌ្ឍកសិកម្មនៅកម្ពុជា ដោយផ្ដោតលើផលិតកម្ម និងការនាំចេញស្រូវ ។ លោកឧកញ៉ា ភូ ពុយ ប្រធានសម្ព័ន្ធសមាគមម៉ាស៊ីនកិនស្រូវកម្ពុជា បានផ្ដល់ជាមតិយោបល់ ស្ដីពីសក្ដានុពលយ៉ាងច្រើនរបស់កម្ពុជាក្នុងការកិនស្រូវ និងនាំចេញអង្ករ ។

តារាង ១: ផលិតភាពស្រូវឆ្នាំ១៩៩៤-២០០៨ (តោន/ហិកតា)

| | ប្រ៊ុយណេ | កម្ពុជា | ឥណ្ឌូនេស៊ី | ឡាវ | ម៉ាឡេស៊ី | ភូមា | ហ្វីលីពីន | ថៃ | វៀតណាម |
|---|---|---|---|---|---|---|---|---|---|
| 1994 | 1.67 | 1.49 | 4.35 | 2.58 | 3.06 | 3.17 | 2.89 | 2.35 | 3.57 |
| 1995 | 1.64 | 1.79 | 4.35 | 2.53 | 3.16 | 2.98 | 2.80 | 2.42 | 3.69 |
| 1996 | 1.65 | 1.81 | 4.42 | 2.55 | 3.25 | 3.06 | 2.86 | 2.41 | 3.77 |
| 1997 | 1.65 | 1.77 | 4.43 | 2.76 | 3.07 | 3.08 | 2.93 | 2.38 | 3.88 |
| 1998 | 1.65 | 1.79 | 4.20 | 2.71 | 2.88 | 3.13 | 2.70 | 2.47 | 3.96 |
| 1999 | 0.53 | 1.94 | 4.25 | 2.93 | 2.94 | 3.24 | 2.95 | 2.42 | 4.10 |
| 2000 | 0.65 | 2.12 | 4.40 | 3.06 | 3.06 | 3.38 | 3.07 | 2.61 | 4.24 |
| 2001 | 0.73 | 2.07 | 4.39 | 3.13 | 3.11 | 3.42 | 3.19 | 2.62 | 4.29 |
| 2002 | 0.73 | 1.92 | 4.47 | 3.27 | 3.24 | 3.42 | 3.28 | 2.61 | 4.59 |
| 2003 | 0.79 | 2.10 | 4.54 | 3.14 | 3.36 | 3.55 | 3.37 | 2.65 | 4.64 |
| 2004 | 0.82 | 1.98 | 4.54 | 3.28 | 3.33 | 3.79 | 3.51 | 2.86 | 4.86 |
| 2005 | 0.87 | 2.48 | 4.57 | 3.49 | 3.42 | 3.75 | 3.59 | 2.96 | 4.89 |
| 2006 | 1.22 | 2.49 | 4.62 | 3.35 | 3.39 | 3.80 | 3.68 | 2.92 | 4.89 |
| 2007 | 1.20 | 2.62 | 4.71 | 3.47 | 3.53 | 3.84 | 3.80 | 3.01 | 4.99 |
| 2008 | 1.20 | 2.75 | 4.89 | 3.47 | 3.57 | 3.72 | 3.77 | 2.97 | 5.22 |
| មធ្យមភាគ | 1.13 | 2.07 | 4.47 | 3.05 | 3.23 | 3.42 | 3.23 | 2.64 | 4.37 |
| អត្រាកំណើន | 1.67 | 4.84 | 0.88 | 2.21 | 1.16 | 1.20 | 2.00 | 1.73 | 2.78 |

*ប្រភព: FAO*

នៃផលិតផលកសិកម្មសរុប ឬ ៩% នៃ ផសស ក្នុងអំឡុងឆ្នាំ១៩៩៤-២០០៦ ។

## ផលិតកម្មស្រូវ

ពីឆ្នាំ១៩៩៤ ដល់ ២០០៨ ផលិតកម្មស្រូវកើនឡើងទ្វេដង ដោយសារកំណើនផលិតភាព និងផ្ទៃដីដាំដុះ ប៉ុន្តែនៅចុងទសវត្សរ៍ ១៩៩០ វាមានអត្រាកំណើនជាមធ្យមកម្រិតទាបត្រឹម ១% ហើយ ចាប់ពីឆ្នាំ២០០២ មក អត្រាកំណើននេះ ប្រែប្រួលឡើងចុះខ្លាំងណាស់ ។ ផលិតកម្មស្រូវ ពឹងផ្អែកជាខ្លាំងលើអាកាសធាតុ ។ ឧទាហរណ៍ក្នុងឆ្នាំ២០០៤ ផលស្រូវសរុបមាន ៤,១លានតោន ឬ ធ្លាក់ចុះ ១១% បើធៀបនឹងឆ្នាំ២០០៣ ដោយសារមានគ្រោះរាំងស្ងួតធ្ងន់ធ្ងរនៅតាមខេត្តជាច្រើន (NIS 2008) ។ នៅឆ្នាំ២០០៥ ផលិតកម្មស្រូវ ឡើងខ្ពស់បំផុតដល់ ៥,៩លានតោន ឬ កើន ៤៤% ធៀបនឹងឆ្នាំ២០០៤ ដោយសារអាកាសធាតុអំណោយផលល្អ និង ទិន្នផលទាបខុសប្រក្រតី ក្នុងឆ្នាំ២០០៤ ដែលបង្កឡើងដោយគ្រោះរាំងស្ងួត ។

ជាមធ្យម ទិន្នផលស្រូវក្នុងមួយហិកតា កើន ៤,៨% ក្នុងមួយឆ្នាំ ដែលជាអត្រាខ្ពស់បំផុត ធៀបនឹងប្រទេសជិតខាងកម្ពុជា ។ ទិន្នផលស្រូវកើនពី ១,៩៩តោន/ហិកតា នៅឆ្នាំ១៩៩៤ ដល់ ២,៧៥តោន/ហិកតា នៅឆ្នាំ២០០៨ (តារាង ១) ។ កំណើននេះ ឆ្លុះបញ្ចាំងពីលទ្ធភាពកាន់តែប្រសើរក្នុងការមានជី និងធាតុចូលផ្សេងទៀតប្រើប្រាស់ ជាជាងការប្រើពូជស្រូវទិន្នផលខ្ពស់ (Agrifood Consulting International 2006, cited in Yu & Fan 2009) ។ ទោះបីមានកំណើនបែបនេះក្តី កម្ពុជានៅតែស្ថិតក្នុងចំណោមប្រទេសមានផលិតភាពស្រូវទាបបំផុតក្នុងតំបន់អាស៊ីខាងត្បូង អាស៊ីអាគ្នេយ៍ និងអាស៊ីខាងកើត ។ ទិន្នផលទាបនេះ បណ្តាលមួយផ្នែកពីផលិតភាពដីទាប ដែលបង្ហាញពីតម្រូវការកែលំអបន្ថែមនូវបច្ចេកវិទ្យាផលិតកម្ម (Yu & Fan 2009) ។ ទិន្នផលទាបនាបច្ចុប្បន្នក៏បង្ហាញដែរថា កម្ពុជានៅមានសក្តានុពលច្រើន សំរាប់បង្កើនផលិតកម្មកសិកម្ម ដូច្នេះ ការបង្កើនទិន្នផលស្រូវ គួរកំណត់ថាជាប្រភពដ៏សំខាន់មួយនៃកំណើនវិស័យកសិកម្ម ។

## តម្រូវការក្នុងស្រុកជាអង្ករសំរាប់បរិភោគ និងអង្ករសំរាប់នាំចេញ

គេប៉ាន់ស្មានថា តំរូវការអង្កររបស់ប្រជាជនកម្ពុជា មានប្រហែល ១៤៣គីឡូក្រាម/នាក់/ឆ្នាំ (MAFF 2009) ។ ដូច្នេះ យោងតាមចំនួនប្រជាជនសរុបប៉ាន់ស្មាន (NIS 2008) តម្រូវការក្នុងស្រុកសរុបនូវអង្ករ កើនឡើងពី ១,៤លានតោន (ស្មើនឹង ២,២លានតោនស្រូវ) ក្នុងឆ្នាំ១៩៩៤ ដល់ ២,១លានតោន (ស្មើនឹង ៣,៣លានតោនស្រូវ) ក្នុងឆ្នាំ២០០៨ ។ នៅឆ្នាំ១៩៩៥ ផលិតកម្មស្រូវកើនដល់កម្រិតគ្រប់គ្រាន់ សំរាប់តម្រូវការក្នុងស្រុក ហើយអតិរេកស្រូវបានកើនជាខ្លាំងក្នុងរយៈពេលបីឆ្នាំចុងក្រោយ រហូតដល់ ២,៨លានតោន (ឬ ១,៦លានតោនអង្ករ) នៅក្នុងឆ្នាំ២០០៨ ។

កម្ពុជា ចាប់ផ្តើមនាំចេញអង្ករឡើងវិញនៅឆ្នាំ១៩៩៥ (Hing et al. 2007) បន្ទាប់ពីបានផ្អាកអស់ ២០ឆ្នាំ ដោយសារសង្គ្រាម និងភាពឯកោខាងនយោបាយ ។ ទោះយ៉ាងនេះក្តី ទិន្នន័យអង្ករនាំចេញ

ក្រាហ្វិក ១: តម្រូវការក្នុងស្រុកនូវអង្ករ ឆ្នាំ១៩៩៤-២០០៨




*ប្រភព: ការគណនារបស់អ្នកនិពន្ធ ដោយផ្អែកលើ IS (2008)*

តារាង ២: ការនាំចេញអង្ករឆ្នាំ២000-0៨

| | 2001 | 2002 | 2003 | 2004 | 2005 | 2006 | 2007 | 2008 | 2000-2008 |
|---|---|---|---|---|---|---|---|---|---|
| អង្ករនាំចេញ (ពាន់តោន) | 15.02 | 15.50 | 2.28 | 4.94 | 5.98 | 5.72 | 4.37 | 6.39 | 6.74 |
| អង្ករនាំចេញ (ពាន់តោន នៃបរិមាណស្រូវ) | 23.84 | 24.61 | 3.62 | 7.83 | 9.50 | 9.08 | 6.93 | 10.14 | 10.70 |
| អតិរេកស្រូវ (ពាន់តោន) | 812 | 518 | 1,234 | 723 | 2,257 | 2,453 | 2,618 | 2,620 | 1,561 |
| ប្រាក់ចំណូលសក្ដានុពលទទួលបានពីការនាំចេញ (លានដុល្លារ)* | 76 | 55 | 130 | 97 | 341 | 383 | 485 | 857 | |
| ប្រាក់ចំណូលសក្ដានុពលទទួលបានពីការនាំចេញ (លានដុល្លារ)** | 88 | 62 | 152 | 108 | 405 | 471 | 541 | 1,089 | |
| អង្ករនាំចេញ ធៀបនឹងអតិរេកអង្ករ | 0.029 | 0.048 | 0.003 | 0.011 | 0.004 | 0.004 | 0.003 | 0.004 | 0.01 |

*សំគាល់: * ថ្លៃអង្ករនាំចេញ (Viet25-FOB) * * ថ្លៃអង្ករនាំចេញ (Thai5-FOB)*

*ប្រភព: អគ្គនាយកដ្ឋានគយ និងរដ្ឋាករ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ; IS (2008)*

ជាផ្លូវការសំរាប់ឆ្នាំ២000-0៨ របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករ បង្ហាញនូវបរិមាណអង្ករនាំចេញដ៏តិចតួច ដែលមិនឆ្លុះបញ្ចាំងពីអតិរេកផលិតកម្មអង្ករទេ ។ តាមទិន្នន័យនេះ កម្ពុជាបាននាំចេញអង្ករ ៤៥0តោន នៅឆ្នាំ២000 ប្រហែល ១៥.000តោន/ឆ្នាំ នៅឆ្នាំ២00១-0២ និង ៤.៩៥0តោន/ឆ្នាំ នៅឆ្នាំ ២00៣-0៨ (តារាង ២) ។ តួលេខនេះបង្ហាញថា គិតជាមធ្យមមានតែ ១% នៃអតិរេកស្រូវប៉ុណ្ណោះ ដែលគេបាននាំចេញជាអង្ករ នៅចន្លោះឆ្នាំ ២000 និង ២00៨ ។ ក្នុងការសិក្សាខ្លះ គេបានកត់ត្រាថា អតិរេកស្រូវមួយភាគធំ ត្រូវបានដឹកជញ្ជូនជាលក្ខណៈមិនផ្លូវការទៅកាន់ប្រទេសថៃ និងវៀតណាម ដើម្បីកិនជាអង្ករសំរាប់នាំចេញដោយប្រទេសទាំងនោះ (Hing et al. 2007, Sin 2009) ។

ធនាគារពិភពលោក (២00៣) បានរាយការណ៍ថា ក្នុងឆ្នាំ ២00១ កម្ពុជានាំចេញអង្ករប្រហែល ៦0.000តោន គឺច្រើនជាងតួលេខផ្លូវការ ៤ដង ។ នៅឆ្នាំដដែលនោះ ស្រូវ ៤៥0.000តោន ដែលមានតម្លៃ ៦៩,៧លានដុល្លារ (ប្រសិនបើធ្វើការជួញដូរតាមច្រកផ្លូវការ) ត្រូវបានដឹកជញ្ជូនជាលក្ខណៈមិនផ្លូវការទៅប្រទេសថៃ នឹងវៀតណាម (World Bank 2003) ។ តួលេខបូកចូលគ្នានៃអង្ករ និងស្រូវ បាននាំចេញទាំងនោះ វាស្មើនឹង ៦៧% នៃអតិរេកស្រូវ (៨១២.000តោន) ក្នុងឆ្នាំនោះ ដូច្នេះ មានអតិរេកស្រូវ ៣៣% ទៀត ដែលនៅសល់ក្នុងប្រទេស ។[២]

## សមត្ថភាពកិនស្រូវ

សមត្ថភាពកិនស្រូវ ជាបញ្ហាប្រឈមសំខាន់មួយ ចំពោះដំណើរការផលិតអង្ករនៅកម្ពុជា ។ ក្នុងមួយឆ្នាំ កម្ពុជាអាចផលិតស្រូវបាន ៤,១២លានតោន ប៉ុន្តែធនាគារពិភពលោក (២00៣) ប៉ាន់ស្មានថាកម្ពុជាមានសមត្ថភាពកិនស្រូវត្រឹមតែ ១,៣១លានតោនប៉ុណ្ណោះ ដូច្នេះ មានស្រូវ ២,៨១លានតោនទៀត ដែលកម្ពុជាមិនអាចកិនបាន ។ តួលេខនេះបង្ហាញថា កម្ពុជាត្រូវបង្កើនសមត្ថភាពកិនស្រូវយ៉ាងហោចណាស់ចំនួន ៣ដងថែមទៀត ដើម្បីបំពេញតម្រូវការក្នុងស្រុក ក្នុងឆ្នាំ២00៨ (តារាង ៣) ។

ដំណើការកែច្នៃអង្ករ ប្រឈមមុខនឹងឧបសគ្គមួយចំនួន ។ ទីមួយ រោងចក្រកិនស្រូវមួយចំនួនធំ ពឹងផ្អែកលើម៉ាស៊ីនចាស់ៗ ដែលធ្វើឲ្យគ្រាប់អង្ករបាក់អស់យ៉ាងច្រើន ហើយតម្លៃអង្ករក៏ថយចុះ ។ អង្ករកម្ពុជា មានគ្រាប់អង្ករបាក់អស់ ៣៥% ហើយត្រូវបានចាត់ទុកជាអង្ករធុនអន់ បើធៀបនឹងអង្ករថៃប្រភេទគ្រាប់វែង ឬអង្ករវៀតណាម ដែលមានគ្រាប់បាក់ តិចជាង ៥% ។ គ្រាប់ពូជច្រើនប្រភេទលាយឡំគ្នា (ពូជមិនសុទ្ធ) និងការចាត់ចែងទុកដាក់មិនសូវល្អក្រោយពេលប្រមូលផល ក៏បង្កើនភាគរយអង្ករបាក់ដែរ ។ ទីពីរ បន្ទុកចំណាយខ្ពស់លើឥណទាន និងកង្វះទុនបង្វិល បានកាត់បន្ថយលទ្ធភាពម្ចាស់រោងម៉ាស៊ីនកិនស្រូវ ក្នុងការទិញស្រូវពីកសិករ និងកែលំអគ្រឿងម៉ាស៊ីន ។ ប្រធានសម្ព័ន្ធសមាគមម៉ាស៊ីនកិនស្រូវកម្ពុជា បញ្ជាក់ថា ម្ចាស់រោងម៉ាស៊ីនកិនស្រូវ ត្រូវការកំចីជាង ៣៧៥លានដុល្លារ សំរាប់ទិញអតិរេកស្រូវនៅរដូវស្រូវជន់ (The Economy Today 2008) ។ មកទល់ពេលនេះ សមាគមទទួលបានកំចីតិចតួចប៉ុណ្ណោះពីរដ្ឋាភិបាល ធនាគារពាណិជ្ជ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ។ ទីបី ម្ចាស់រោងម៉ាស៊ីនកិនស្រូវ ខ្វះខាតលទ្ធភាពចូលទៅទីផ្សារអន្តរជាតិ ពីព្រោះពុំមានលទ្ធភាពផលិតអង្ករគុណភាពល្អ ឲ្យបានច្រើនជាទៀងទាត់បាន ។

## កត្តាកំណត់ផលិតភាពស្រូវ

ដូចមានបញ្ជាក់ក្នុងផ្នែកទី២ ផលិតភាពស្រូវនៅកម្ពុជា ស្ថិតក្នុងកំរិតទាបជាងគេបំផុតនៅក្នុងតំបន់ ។ ការសិក្សាមុនៗ (e.g. World Bank 2006; Markussen 2008) បង្ហាញថា កម្មសិទ្ធិដីមានសុវត្ថិភាព តែងជះឥទ្ធិពលជាវិជ្ជមានទៅលើផលិតភាពកសិកម្ម ។ ផ្អែកលើអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា (CSES) ឆ្នាំ២00៤ ធនាគារពិភពលោក (២00៦) រកឃើញថា កម្មសិទ្ធិដីធ្លីក្នុងទំរង់ជាលិខិតបញ្ជាក់ការកាន់កាប់ បង្កាន់ដៃទទួលពាក្យសុំកម្មសិទ្ធិ ឬឯកសារផ្លូវការផ្សេងទៀត ធ្វើឲ្យទិន្នផលដំណាំ កើន ៦៥% ។ ដោយប្រើប្រាស់ទិន្នន័យដដែលនេះ Markussen (២00៨) បាន

២ បើគិតតាមអត្រាបំប្លែង 0,៦៣ នោះ មានអង្ករប្រហែល ៦0.000តោន ត្រូវបានកិនយកពីស្រូវ ។ អត្រាបំប្លែង ប្រែប្រួលទៅតាមទំហំនៃរោងម៉ាស៊ីនកិនស្រូវ ។ សំរាប់រោងម៉ាស៊ីនធ្វើអាជីវកម្មកិនស្រូវខ្នាតតូច អត្រាបំប្លែងទំនងជាតិចជាង 0,៥៥ (World Bank 2003) ។

តារាង ៣: សមត្ថភាពកិនស្រូវ

| | ផលិតកម្មស្រូវ (ពាន់តោន) | សមត្ថភាពកិនស្រូវសរុប (ពាន់តោន) | ឱនភាពសមត្ថភាពកិនស្រូវ (ពាន់តោន) | ការប្រើប្រាស់ក្នុងស្រុក (ពាន់តោន) | សមត្ថភាពកិនស្រូវសរុប/ការប្រើប្រាស់ក្នុងស្រុក | កំហាតបង់នៃប្រាក់ចំណូលពីការនាំចេញ (លានដុល្លារ) |
|---|---|---|---|---|---|---|
| ធនាគារពិភពលោក (2003) | 4120 | 1310 | 2810 | | | |
| 2008 សេណារីយ៉ូ 1 | 7150 | 1310 | 5840 | 3327 | 0.39 | 1519 |
| 2008 សេណារីយ៉ូ 2 | 7150 | 2620 | 4530 | 3327 | 0.79 | 1178 |
| 2008 សេណារីយ៉ូ 3 | 7150 | 3930 | 3220 | 3327 | 1.18 | 838 |

*ប្រភព: WB(2003), IS(2008), និង ការប៉ាន់ស្មានរបស់អ្នកនិពន្ធ*

រកឃើញលទ្ធផលស្រាវជ្រាវស្របគ្នា បើទោះជាកំណើនផលិតភាពនៅក្នុងការស្រាវជ្រាវរបស់គាត់ បានត្រឹមតែពាក់កណ្តាលនៃតួលេខដែលធនាគារពិភពលោកបានរកឃើញក្តី ។ ទោះបីមានការទទួលស្គាល់ជាទូទៅថា កម្មសិទ្ធិដីមានការផលប៉ះពាល់ល្អលើផលិតភាពកសិកម្មក្តី ក៏មិនទាន់មានកំណត់អ្វីឲ្យជាក់លាក់ពីឥទ្ធិពលទៅលើផលិតកម្មស្រូវទេ ។ លោក គុង គឹមស៊ីន (ឯកសារចេញផ្សាយឆាប់ៗ) ព្យាយាមបំពេញចន្លោះប្រហោងនេះ ដោយប្រើប្រាស់ CSES 2007 ហើយកត់សម្គាល់ថា ការដាំដុះលើដីដែលបានចុះបញ្ជីមានក្រដាសស្នាមត្រឹមត្រូវ ផ្តល់ផលជាមធ្យមច្រើនជាងការដាំដុះលើដីដទៃទៀត ២០% ។ ម្យ៉ាងវិញទៀត ការសិក្សារបស់លោក គុង គឹមស៊ីន បញ្ជាក់ថា ធាតុចូលផ្សេងទៀតមានដូចជា គ្រាប់ពូជ ជី ថ្នាំសំលាប់សត្វល្អិត ជីលាមកសត្វ និងជីកំប៉ុស អគ្គិសនីសំរាប់បំរើការដាំដុះ ការដឹកជញ្ជូនធាតុចូលជាសំភារៈ ពលកម្មស៊ីឈ្នួល ការស្រោចស្រព និងបរិក្ខារកសិកម្មទំនើបៗមានដូចជា ត្រាក់ទ័រ គោយន្ត និងម៉ាស៊ីនបូមទឹកជាដើម សុទ្ធតែបានជួយចូលរួមចំណែកជាវិជ្ជមានក្នុងផលិតកម្មស្រូវ ។ លទ្ធផលស្រាវជ្រាវគួរចាប់អារម្មណ៍ផ្សេងៗទៀត គឺការដាំដុះលើផ្ទៃដីតូច តែងតែមានប្រសិទ្ធភាពជាងលើផ្ទៃដីធំ គម្រោងអភិវឌ្ឍន៍កសិកម្មរបស់រដ្ឋាភិបាល គេសង្កេតឃើញថាពុំមានឥទ្ធិពលវិជ្ជមានទេ ប៉ុន្តែគម្រោងសហការគ្នារវាងរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលបានជួយបង្កើនផលិតភាពកសិកម្ម ។ គ្រោះរាំងស្ងួត មានផលប៉ះពាល់ជាអវិជ្ជមាន រយៈពេលវែងលើផលិតកម្មស្រូវ តួយ៉ាងគ្រោះរាំងស្ងួតនៅក្នុងរដូវនេះ នឹងប៉ះពាល់ដល់ផលិតភាពកសិកម្មនៅរដូវក្រោយ ។

## យុទ្ធសាស្ត្ររបស់រដ្ឋាភិបាល

រដ្ឋាភិបាល បានផ្តល់អាទិភាពដល់ការជំរុញកសិកម្ម តាមរយៈការបង្កើនផលិតភាព ការធ្វើពិពិធកម្ម និងការលើកកំពស់កសិ-ឧស្សាហកម្ម ។ ប៉ុន្តែរដ្ឋាភិបាលបានបង្វែរចំណាប់អារម្មណ៍ពីការពង្រីកផ្ទៃដីដាំដុះ មកជំរុញការដាំដុះបែបអតិផលលើផ្ទៃដីមានស្រាប់វិញ (តារាង ៤) ។ ចំណែកវិស័យកសិកម្មក្នុងថវិកាជាតិ មានកម្រិត ២% ជាមធ្យម សំរាប់ឆ្នាំ ២០០៨-១៣ ឬ ០,២% ឯកតាភាគរយ (0.2 percentage point) ទាបជាងក្នុង ឆ្នាំ១៩៩៩-២០០៧ (RGC 2009) ។ ជាទូទៅ ការបែងចែកថវិកាសំរាប់វិស័យកសិកម្មគ្មានការប្រែប្រួលជាដុំកំភួនទេ ក្នុងទសវត្សរ៍មុននេះ ។

តាំងពីបានចូលជាសមាជិកអាស៊ាន និងអង្គការពាណិជ្ជកម្មពិភពលោកមក កម្ពុជាបានធ្វើសេរីភាវូបនីយកម្មគោលនយោបាយសំរាប់ការនាំចេញផលិតផលកសិកម្ម ។ មួយវិញទៀត គំនិតផ្តួចផ្តើមបើកចំហពាណិជ្ជកម្មគ្រប់យ៉ាងក្រៅពីអាវុធ ដែលបានធ្វើឡើងក្នុងឆ្នាំ២០០១ ដោយសហភាពអឺរ៉ុប មានសារៈសំខាន់សំរាប់បើកផ្លូវឲ្យដល់ការនាំចេញអង្ករពីកម្ពុជា ទៅកាន់ទីផ្សារសហភាពអឺរ៉ុប ។ គំនិតផ្តួចផ្តើមនេះ អនុញ្ញាតឲ្យមានការនាំចូលទំនិញដោយគ្មានជាប់ពន្ធគយ និងកូតា (លើកលែងតែអាវុធចេញ) ពីបណ្តាប្រទេសអភិវឌ្ឍន៍តិច ។

## ផលប៉ះពាល់ខាងគោលនយោបាយ

ទោះបីផលិតភាពស្រូវកម្ពុជា នៅទាបជាងប្រទេសជិតខាងក្តី ប៉ុន្តែផលិតកម្មស្រូវសរុបរបស់កម្ពុជា មានច្រើនលើសតម្រូវការក្នុងស្រុក និងមានអតិរេកសំរាប់ការនាំចេញទៀតផង ។ ដោយសារសមត្ថភាពកិនស្រូវរបស់កម្ពុជា នៅមិនទាន់គ្រប់គ្រាន់តាមតម្រូវការ ដូច្នេះ

តារាង ៤: សូចនាករសំខាន់ៗសំរាប់ដំណាំស្រូវ

| សូចនាករសំខាន់ៗ | ឯកតា | 2008 តួលេខពិត | 2009 ប៉ាន់ស្មាន | 2010 ព្យាករណ៍ | 2011 ព្យាករណ៍ | 2012 ព្យាករណ៍ | 2013 ព្យាករណ៍ |
|---|---|---|---|---|---|---|---|
| ដីកំពុងដាំដុះ | ពាន់ហិកតា | 596 | 750 | 950 | 1000 | 1000 | 1000 |
| ស្រូវ៖ ផ្ទៃដីដាំដុះ | លានហិកតា | 2.61 | 2.63 | 2.65 | 2.65 | 2.65 | 2.65 |
| ទិន្នផលក្នុង១ហិកតា | តោន | 2.74 | 2.77 | 2.80 | 2.83 | 2.87 | 3.00 |
| ផលិតកម្មស្រូវ | លានតោន | 7.17 | 7.28 | 7.42 | 7.50 | 7.6 | 7.95 |
| ផ្ទៃដីស្រោចស្រព | ពាន់តោន | 827 | 867 | - | - | - | - |

*ប្រភព: RGC (2009)*

អតិរេកស្រូវភាគច្រើន ក៏ត្រូវបាននាំចេញជាលក្ខណៈក្រៅផ្លូវការទៅប្រទេសថៃ និងវៀតណាម ដើម្បីកិនជាអង្ករ និងនាំចេញបន្តទៀត ។ យោងតាមសក្តានុពលនៃផលិតកម្មស្រូវ កំណើនតំលៃបន្ថែមលើផលស្រូវមានសារៈសំខាន់ណាស់ សម្រាប់កំណើនវិស័យកសិកម្ម និងការកាត់បន្ថយភាពក្រីក្រ ។

គោលនយោបាយរាជរដ្ឋាភិបាល សម្រាប់ឆ្នាំ២០០៩-១៣ មានគោលដៅសម្រេចឲ្យបានកំណើនខ្ពស់ និងមានចីរភាពនៃដំណាំស្រូវ តាមរយៈការបន្តចេញប័ណ្ណកម្មសិទ្ធិដី ជាពិសេសដល់ប្រជាកសិករ ការបង្កើនលទ្ធភាពស្រោចស្រព ការកែលំអប្រព័ន្ធគ្រប់គ្រងទឹកសំរាប់កសិកម្ម ការលើកទឹកចិត្តកសិករឲ្យប្រើបច្ចេកវិទ្យាកសិកម្មថ្មី ការបង្កើនសហប្រតិបត្តិការរវាងរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល ការប្រើដីស្រែឲ្យមានប្រសិទ្ធិភាពខ្ពស់ និងការពន្លឿនការផ្តល់សម្បទានដីដល់កសិករដែលមានដីតិច ។

*លោកឧកញ៉ា ភួ ពុយ បានអំពាវនាវឲ្យមានកិច្ចប្រឹងប្រែងរួមគ្នាជួយដោះស្រាយឧបសគ្គនានា ដើម្បីសំរេចបាននូវសក្តានុពលនៃការនាំចេញអង្ករ៖*

មានសកម្មភាពជាច្រើនត្រូវធ្វើឡើង ដើម្បីកែលំអផលិតកម្ម ការកែច្នៃ និងការនាំចេញអង្ករ ។ សំរាប់ផលិតកម្មគេត្រូវ៖ (១) បង្កើនការផ្គត់ផ្គង់ស្រូវពូជ (មានទាំងកន្លែងផលិតស្រូវពូជផង) ដោយតម្រូវតាមទីផ្សារនាំចេញ (២) កែលំអបច្ចេកទេសផលិតកម្ម និងគ្រប់គ្រង (៣) កែលំអបច្ចេកទេសប្រមូលផល (៤) បង្កើតតំបន់មានសក្តានុពលខ្ពស់ ដែលអាចដាំស្រូវបានពីរដងក្នុងមួយឆ្នាំ (៥) ដាក់អនុវត្តក្របខ័ណ្ឌមួយសំរាប់ការធានាគុណភាព (៦) ត្រូវមានគំនិតផ្តួចផ្តើមរបស់រដ្ឋាភិបាល ជួយគាំទ្រដល់ការដាំដុះបែបពាណិជ្ជកម្ម (៧) ផ្តល់ឥណទានមានការប្រាក់ទាបសមរម្យ សំរាប់រយៈពេលខ្លី មធ្យម និងវែង តាមរយៈស្ថាប័នដែលធ្វើការជិតស្និទ្ធជាមួយកសិករ និងសហគមន៍ ។

ការជំរុញ និងអភិវឌ្ឍន៍ការកែច្នៃ និងវិចខ្ចប់អង្ករ គួរប្រើប្រាស់បរិក្ខារទំនើបៗ និងអនុវត្តតាមស្តង់ដារទីផ្សារអន្តរជាតិ ។ ការងារនេះក៏ត្រូវមានឥណទានមានតម្លៃថោកសមរម្យ សំរាប់ធ្វើវិនិយោគក្នុងរយៈពេលខ្លី មធ្យម និងវែង ។ ទំហំឥណទាន គួរបត់បែនទៅតាមតម្រូវការជាក់ស្តែងរបស់សហគ្រាស ។ រដ្ឋាភិបាលត្រូវចេញមុខធានាដើម្បីឲ្យស្ថាប័នហិរញ្ញវត្ថុ និងធនាគារ ព្រមផ្តល់កំចីទៅឲ្យវិស័យឯកជន ។ មួយវិញទៀត អគ្គិសនី ជាកត្តាសំខាន់បំផុតមួយសំរាប់ការកែច្នៃអង្ករ (និងផលិតផលជាច្រើនទៀត) ។ គួរដាក់អនុវត្តថ្លៃអគ្គិសនី (ទាប) ពិសេសមួយសំរាប់សហគ្រាសកែច្នៃ និងវិចខ្ចប់អង្ករ យ៉ាងហោចណាស់នៅថ្ងៃចុងសប្តាហ៍ ឬនៅពេលយប់ជ្រៅ ។ មធ្យោបាយមួយ សម្រាប់បង្កើនការផ្គត់ផ្គង់អគ្គិសនីតំលៃថោក គឺការអនុញ្ញាតឲ្យវិនិយោគិនធំៗ ផលិតថាមពលអគ្គិសនីដោយខ្លួនឯង ហើយលក់អតិរេកអគ្គិសនីរបស់គេទៅតំបន់ជិតខាងនោះ ។

រដ្ឋាភិបាល គួរជួយស្វែងរកទីផ្សារសំរាប់នាំចេញអង្ករនៅតាមប្រទេស ដូចជា ហ្វីលីពីន ឥណ្ឌូនេស៊ី និងតំបន់អឺរ៉ុប ជាដើម ។ ក្របខ័ណ្ឌច្បាប់ទាក់ទងនឹង កសិកម្ម កសិឧស្សាហកម្ម និងពាណិជ្ជកម្ម ក៏គួរពង្រឹងឡើងដែរ ។ គួរមានច្បាប់តឹងរឹង និងការពង្រឹងអនុវត្តច្បាប់ ស្តីពីការនាំចេញ និងការនាំចូល ។ ការនាំចេញ និងនាំចូលផលិតផលជាក់លាក់មួយចំនួន គួររឹតបន្តឹង ឬហាមឃាត់ ហើយចំពោះផលិតផលឯទៀតគួរបើកទូលាយ ។ សេវាទ្រទ្រង់ពាណិជ្ជកម្មគួរកែលំអថែមទៀត គឺមានដូចជា ការលើកលែងពន្ធ ការកាត់បន្ថយការងារក្រដាសស្នាម ការកាត់បន្ថយចំណាយដឹកជញ្ជូនទាំងតាមផ្លូវគោក និងផ្លូវសមុទ្រ និងការកែលំអសេវាកំពង់ផែ ។ ដើម្បីឲ្យវិស័យឯកជន និងរដ្ឋាភិបាល អនុវត្តបានជោគជ័យនូវសេដ្ឋកិច្ចទីផ្សារសេរី គេត្រូវធ្វើការគណនាជានិច្ច ពីផលចំណេញ និងបន្ទុកចំណាយ ។ គោលការណ៍នេះ អនុវត្តលើគ្រប់វិស័យពាក់ព័ន្ធទាំងអស់ ជាពិសេសកសិកម្ម ឧស្សាហកម្ម និងពាណិជ្ជកម្ម ។

## ឯកសារយោង


The Economy Today (2008), Gold is Money: Cambodian Savings Bank, Volume 2, Number 10, March 1-15 (Phnom Penh: Cambodia)

Hang Chuon Naron (2010), Macroeconomic Development in 2009, Presentation at Cambodian Economic Association Annual Meeting

Hing Vutha, Chan Sophal, and Sok Sina (2007), "Cambodia's Agricultural Production and Trade", Cambodian Economic Review, Cambodian Economic Association (Phnom Penh: Cambodia)

Hossein Jalilian and Glenda Reyes (2010), The Global Financial Crisis Discussion Series, Paper 12: Cambodia Phase 2 (London: ODI)

Markussen Thomas (2008), "Property Rights, Productivity, and Common Property Resources: Insights from Rural Cambodia", World Development, Vol.36, No.11, pp.2277-2296

Ministry of Agriculture, Forestry, and Fisheries (2009), Annual Report for Agriculture Forestry and Fisheries 2008-2009 (Phnom Penh: Cambodia)

National Institute of Statistics (2006, 2007), National Accounts of Cambodia, Ministry of Planning (Phnom Penh: Cambodia)

National Institute of Statistics (2008), Statistical Yearbook of Cambodia, Ministry of Planning (Phnom Penh: Cambodia)

Sin Meng Srun (2009), Rice for Economic Growth and Food Security (memo), Economic, Social and Cultural Council (ECOSOCC) (Phnom Penh: Cambodia)

Yu Bingxin and Fan Shenggen Fan (2009), Rice Production Responses in Cambodia, IFPRI Discussion Paper

Royal Government of Cambodia (2009), National Strategic Development Plan Update 2009-2013, (Phnom Penh: Cambodia)

The World Bank (2003), Towards a Private Sector-led Growth Strategy for Cambodia Volume 1: Value Chain Analysis, East Asia and Pacific Region

The World Bank (2006), Cambodia-Halving Poverty by 2015: Poverty Assessment 2006, East Asia and Pacific Region

Tong Kimsun (forthcoming), Land Tenure and Paddy Productivity: Evidence from Cambodia, Cambodia Development Resource Institute (Phnom Penh: Cambodia)